ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកោះកុង**

សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥២

ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២១

សាលក្រមលេខៈ ៥២ "ក"

ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២១

## គោរពនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកោះកុង

បង្កើតឡើងតាមច្បាប់ស្តីពី ការរៀបចំអង្គការតុលាការ ដែលបានប្រកាសឲ្យប្រើ តាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦.៧.២០១៤ ។

បានបើកសវនាការជាសាធារណៈ នៅសាលជំនុំជម្រះសាលាដំបូងខេត្តកោះកុង នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ២០២១ វេលាម៉ោង ២,៣០ នាទីរសៀល និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ២,៣០ នាទីរសៀល ដោយមានសមាសភាព ដូចតទៅ៖

<u>ចៅក្រមជំនុំជម្រះ</u>

-ឯកឧត្តម [redacted] ប្រធានសាលាដំបូងខេត្តកោះកុង

<u>តំណាងអយ្យការ</u>

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកោះកុង

<u>ក្រឡាបញ្ជីសវនាការ</u>

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

-ដើម្បីជំនុំជម្រះលើ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៥២ ចុះថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ ដែលមានជនជាប់ចោទឈ្មោះ [redacted] ភារម្យ ភេទស្រី អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ លក់ដូរ ទីកន្លែងកំណើតនៅ[redacted] ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្ននៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ឪពុកឈ្មោះ [redacted] ជេងឡាយ (ស) ម្តាយឈ្មោះ [redacted] ចេង (រ) ប្តីឈ្មោះ [redacted] មុន មានកូន ០៣នាក់ ជានីតិជន ទោសពីមុន គ្មាន ។ (ឃុំខ្លួនថ្ងៃទី២៣-០១-២០២១) ។

<u>ត្រូវចោទពីបទៈ</u> ឆបោក ប្រព្រឹត្តនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ , ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ ភេទស្រី អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ។

មានមេធាវីឈ្មោះ [redacted] ជាមេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ហាក់ ស្រីមុំ ។

<u>-បានឃើញ</u>ដីកាសន្និដ្ឋានស្ថាពរលេខៈ ៧១ អ.យ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

<u>-បានឃើញ</u>ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ៧៨៧ គ៣/២១ ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកោះកុង ។

-បានឃើញដីកាសម្រេចចាត់តាំងចៅក្រមជំនុំជម្រះលេខ: ១៥៦ ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២១ របស់ឯកឧត្តមប្រធានសាលាដំបូងខេត្តកោះកុង ។

ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ

-កាលពីថ្ងៃទី ២២ ខែមករា ឆ្នាំ២០២១ ឈ្មោះ [redacted] ស្រីមុំ បានមកដាក់ពាក្យបណ្តឹងរាយការណ៍ជូននគរបាលការិយាល័យកម្រិតស្រាលនៃស្នងការនគរបាលខេត្តកោះកុង ប្តឹងពីឈ្មោះ [redacted] ភារម្យ ដែលបានឆបោកខ្លួន កាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៩ ។ បន្ទាប់ពីទទួលបានពាក្យបណ្តឹង កម្លាំងការិយាល័យព្រហ្មទណ្ឌកម្រិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តកោះកុង បានធ្វើការស៊ើបអង្កេត និងបានឃាត់ខ្លួនជនសង្ស័យ ឈ្មោះ [redacted] ភារម្យ និងបានកសាងសំណុំរឿងបញ្ជូនមកសាលាដំបូងខេត្តកោះកុង ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ។

ក្រោយពេលស៊ើបអង្កេត បានឲ្យដឹងថា កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ឈ្មោះ [redacted] ភារម្យ បានខ្ចីប្រាក់ពីឈ្មោះ [redacted] ស្រីមុំ ចំនួន ៥០.០០០ “ប្រាំម៉ឺន” ដុល្លារអាមេរិក ដោយបង់ការប្រាក់ចំនួន ៧% ក្នុង ០១ខែ ដោយធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវ ហើយដើម្បីធានាលើបំណុល ឈ្មោះ [redacted] ភារម្យ ក៏បានយកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ០៩០៥០១០-០៥០០ ចំនួន ០១ច្បាប់ (ថតចម្លង) ប្រគល់ឲ្យទៅឈ្មោះ [redacted] ស្រីមុំ ថែរក្សា ។ ក្នុងអំឡុងពេល នៃការខ្ចីប្រាក់នេះ ឈ្មោះ [redacted] ភារម្យ ពុំបានបង់ការប្រាក់ឲ្យទៅឈ្មោះ [redacted] ស្រីមុំ ទៀងទាត់នោះទេ ហើយនៅពេលឈ្មោះ [redacted] ស្រីមុំ ទៅទារប្រាក់ គឺឈ្មោះ [redacted] ភារម្យ តែងតែគេចវេសរហូត ។ លុះក្រោយមកទៀតឈ្មោះ [redacted] ស្រីមុំ ក៏បានធ្វើការស្រាវជ្រាវ ដឹងថា ឈ្មោះ [redacted] ភារម្យ បានជំពាក់ប្រាក់ធនាគារ និងជំពាក់ប្រាក់ម្ចាស់បំណុលជាច្រើននាក់ផ្សេងទៀត ។ ហើយចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ០៩០៥០១០-០៥០០ ដែលឈ្មោះ [redacted] ភារម្យ យកមកប្រគល់ឲ្យ ឈ្មោះ [redacted] ស្រីមុំ នោះ គឺច្បាប់ចម្លង ចំណែកឯវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ០៩០៥០១០-០៥០០ ច្បាប់ដើម គឺឈ្មោះ [redacted] ភារម្យ បានដាក់បញ្ចាំនៅធនាគារផងដែរ ដោយមើលឃើញពីចេតនាទុច្ចរិត ក្នុងការឆបោក របស់ឈ្មោះ [redacted] ភារម្យ ទើបបានជាឈ្មោះ [redacted] ស្រីមុំ ប្តឹងទៅសមត្ថកិច្ច ដើម្បីចាត់ការតាមនិតិច្បាប់តែម្តង ។

នាពេលសវនាការ

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ បានឆ្លើយបញ្ជាក់ក្នុងពេលសវនាការថា: កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ឈ្មោះ [redacted] ភារម្យ បានមកខ្ចីចងការប្រាក់ពីខ្លួន ចំនួន ៥០.០០០ “ប្រាំម៉ឺន” ដុល្លារអាមេរិក ពីខ្លួន និងបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ចំនួន ០២លើក ក្នុងថ្ងៃ តែមួយ គឺថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ លើកទី ១ ចំនួន ២០.០០០ “ពីរម៉ឺន” ដុល្លារអាមេរិក, លើកទី ២ ចំនួន ៣០.០០០ “បីម៉ឺន” ដុល្លារមេរិក ដោយខ្លួនយកការប្រាក់ចំនួន ៧% ស្មើនឹង ៣.៥០០ “បីពាន់ប្រាំរយ” ដុល្លារអាមេរិក មានសាក្សីឈ្មោះ [redacted] សារិន ជាអធិការស្រុកមណ្ឌលសីមា ខេត្តកោះកុង ចុះហត្ថលេខានឹងលឺ និងទទួលស្គាល់ថាឈ្មោះ [redacted] ភារម្យ បានខ្ចីប្រាក់ពីខ្លួន សរុបចំនួន ៥០.០០០ “ប្រាំម៉ឺន” ដុល្លារអាមេរិក ពិតប្រាកដមែន ។ ដោយឈ្មោះ ហេង ភារម្យ បានយកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ០៩០៥០១០-០៥០០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩ (ថតចម្លង) ដាក់បញ្ចាំនៅនឹងខ្លួន ។ មូលហេតុដែលខ្លួនទុកចិត្តទទួលយកប្លង់ (ថតចម្លង) គឺដោយសារតែឈ្មោះ [redacted] ភារម្យ បានអះអាងថា ប្លង់ពិតគឺនៅធនាគារកាណាឌីយ៉ា ចាំទៅលូសប្លង់ពិតមកឲ្យខ្លួនវិញ ហើយម្យ៉ាងទៀត ឈ្មោះ [redacted] ភារម្យ ជាមិត្តភក្តិជិតស្និតរបស់ខ្លួន ទើបខ្លួនជឿទុកចិត្តឲ្យខ្ចីប្រាក់ ។ ឈ្មោះ [redacted] ភារម្យ បានបង់ប្រាក់ការឲ្យមកខ្លួន បានត្រឹមតែ ០២ខែប៉ុណ្ណោះ ក្រោយមកក៏មិនបានបង់ឲ្យខ្លួនទេ ។ រហូតចូលដល់ក្នុង

ខែ កញ្ញា ឆ្នាំ ២០១៩ ឈ្មោះ [redacted] ភារម្យ បានខ្ចីប្រាក់ពីខ្លួន ចំនួន ១០.០០០ "មួយម៉ឺន" ដុល្លារអាមេរិក បន្ថែមទៀត តែមិនបានធ្វើកិច្ចសន្យាទេ ។ ក្រោយមកនៅក្នុងខែមីនា ឆ្នាំ ២០២០ ឈ្មោះ [redacted] ភារម្យ មកខ្ចីប្រាក់ខ្លួនទៀត ចំនួន ១២.០០០ "មួយម៉ឺនពីរពាន់" ដុល្លារអាមេរិក ដោយខ្លួនបានយកប្លង់ផ្ទះជាឈ្មោះរបស់ខ្លួនផ្ទាល់ ទៅដាក់បញ្ចាំនៅនឹងគេ ដើម្បីយកប្រាក់មកឲ្យឈ្មោះ [redacted] ភារម្យ ខ្ចី ។ ក្រោយមកនៅថ្ងៃខែមិនចាំ ឈ្មោះ [redacted] ភារម្យ បានមកខ្ចីប្រាក់ពីម្តាយក្មេកខ្លួន ចំនួន ៥០០ "ប្រាំរយ" ដុល្លារ ថែមទៀត សរុបប្រាក់ដើមជំពាក់ គឺចំនួន ៧២.៥០០ "ប្រាំពីរម៉ឺនពីរពាន់ប្រាំរយ" ដុល្លារអាមេរិក ។

ក្នុងអំឡុងពេលនៃការខ្ចីប្រាក់នេះ ឈ្មោះ [redacted] ភារម្យ ពុំបានបង់ការប្រាក់ឲ្យមកខ្លួនទៀងទាត់នោះទេ ហើយនៅពេលដែលខ្លួនទៅទារប្រាក់ គឺឈ្មោះ [redacted] ភារម្យ តែងតែឆ្លើយគេចវេសរហូត ។ លុះក្រោយមកខ្លួនក៏បានស្រាវជ្រាវ នឹងថា ឈ្មោះ [redacted] ភារម្យ បានជំពាក់ប្រាក់ធនាគារនិងជំពាក់ប្រាក់ម្ចាស់បំណុលជាច្រើននាក់ផ្សេងទៀត ហើយចំពោះវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ០៩០៥០១០-០៥០០ ដែលឈ្មោះ [redacted] ភារម្យ យកមកប្រគល់ឲ្យខ្លួននោះគឺជាច្បាប់ចម្លង ចំណែកឯវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ០៩០៥០១០-០៥០០ ច្បាប់ដើម គឺឈ្មោះ [redacted] ភារម្យ បានដាក់បញ្ចាំនៅធនាគាររួចទៅហើយ ដោយខ្លួនមើលឃើញពីចេតនាទុច្ចរិត ក្នុងការឆបោក របស់ឈ្មោះ [redacted] ភារម្យ ទើបខ្លួនប្តឹងទៅសមត្ថកិច្ច ដើម្បីចាត់ការ តាមនីតិវិធីច្បាប់តែម្តង ។ ក្នុងពេលនេះ ខ្លួនសុំប្តឹងទាមទារជំពាក់ពីឈ្មោះ [redacted] ភារម្យ ចំនួន ៧០.០០០ "ប្រាំពីរម៉ឺន" ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន ២.០០០ "ពីរពាន់" ដុល្លារអាមេរិក ។

-ជនជាប់ចោទឈ្មោះ [redacted] ភារម្យ បានឆ្លើយបំភ្លឺក្នុងពេលសាកសួរថា: ខ្លួនពិតជាបានខ្ចីប្រាក់ពីឈ្មោះ [redacted] ស្រីមុំ ចំនួន ៥០.០០០ "ប្រាំម៉ឺន" ដុល្លារអាមេរិក ប្រាកដមែន ។ ប្រាក់ចំនួនខាងលើនេះ ខ្លួនបានទូរស័ព្ទគេខ្ចីពីឈ្មោះ [redacted] សយ ដែលជាឪពុកក្មេករបស់ឈ្មោះ ហាក់ ស្រីមុំ ។ ហើយប្រាក់ចំនួន ៥០.០០០ "ប្រាំម៉ឺន" ដុល្លារអាមេរិក នេះ ឈ្មោះ [redacted] ស្រីមុំ ជាអ្នកប្រគល់ឲ្យមកខ្លួន លើកទី ១ ចំនួន ២០.០០០ "ពីរម៉ឺន" ដុល្លារអាមេរិក, លើកទី ២ ចំនួន ៣០.០០០ ដុល្លារអាមេរិក ដោយបានធ្វើកិច្ចសន្យាក្នុងថ្ងៃតែមួយ គឺថ្ងៃ ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ និងឲ្យការប្រាក់ចំនួន ៧% ស្មើនឹង ៣.៥០០ "បីពាន់ប្រាំរយ" ដុល្លារអាមេរិក មានសាក្សីឈ្មោះ [redacted] សារិន ជាអធិការស្រុកមណ្ឌលសីមា ខេត្តកោះកុង ចុះហត្ថលេខានឹងលី និងទទួលស្គាល់ថាខ្លួនបានខ្ចីប្រាក់ពីឈ្មោះ [redacted] ស្រីមុំ ចំនួន ៥០.០០០ "ប្រាំម៉ឺន" ដុល្លារអាមេរិក ពិតមែន ដោយខ្លួនបានយកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ០៩០៥០១០-០៥០០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩ (ថតចម្លង) ដាក់បញ្ចាំនឹងឈ្មោះ [redacted] ស្រីមុំ ហើយឈ្មោះ [redacted] ស្រីមុំ ក៏បាននឹងថា វិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ០៩០៥០១០-០៥០០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩ នេះជាច្បាប់ចម្លង ហើយវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ: ០៩០៥០១០-០៥០០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩ ដែលជាច្បាប់ដើម នៅជាប់នៅធនាគារហើយដែរ ដោយសារតែខ្លួននិងឈ្មោះ [redacted] ស្រីមុំ បានព្រមព្រៀងគ្នា ហើយឈ្មោះ [redacted] ស្រីមុំ ជាអ្នកប្រាប់ឲ្យខ្លួនថតចម្លងឲ្យដូចច្បាប់ដើម ដើម្បីយកលុយពីឈ្មោះ [redacted] សយ ត្រូវជាឪពុកក្មេករបស់ឈ្មោះ [redacted] ស្រីមុំ ឲ្យគាត់ជឿ ព្រោះគាត់មិនសូវចេះអក្សរ ព្រោះថាលុយសរុបចំនួន ៥០.០០០ "ប្រាំម៉ឺន" ដុល្លារអាមេរិក ដែលខ្លួនខ្ចីនោះ ជារបស់ឈ្មោះ [redacted] សយ ។ ខ្លួននិងឈ្មោះ ហាក់ ស្រីមុំ ជាមិត្តភក្តិជិតស្និតនឹងគ្នា ទើបឈ្មោះ [redacted] ស្រីមុំ ឲ្យខ្លួនថតចម្លងឲ្យដូចច្បាប់ដើម ដើម្បីឲ្យឪពុកក្មេករបស់ ឈ្មោះ [redacted] ស្រីមុំ ជឿ ។ ក្រោយមកទៀត ខ្លួនពិតជាបានខ្ចីប្រាក់ពីឈ្មោះ [redacted] ស្រីមុំ រហូតបន្ថែមទៀត ចំនួន ២២.៥០០ "ពីរម៉ឺនប្រាំរយ" ដុល្លារអាមេរិក សរុបទាំងអស់ គឺចំនួន ៧២.៥០០ "ប្រាំពីរម៉ឺនពីរពាន់ប្រាំរយ" ដុល្លារអាមេរិក ពិតប្រាកដមែន ។

-សាក្សីឈ្មោះ [redacted] សារិន បានឆ្លើយបញ្ជាក់ក្នុងពេលសវនាការថា: ខ្លួនមិនបានដឹងលឺរឿងបញ្ចាំប្លង់នោះទេ ខ្លួនគ្រាន់តែស៊ីញ៉េដឹងលឺ ថា ឈ្មោះ [redacted] ភារម្យ ខ្ចីលុយ ពីឈ្មោះ [redacted] ស្រីមុំ ចំនួន ០២ដង មួយដង ២ម៉ឺនដុល្លារ, និងមួយដងទៀត ចំនួន ៣ម៉ឺនដុល្លារ តែប៉ុណ្ណោះ រឿងអ្វីផ្សេងទៀត ខ្លួនមិនដឹងលឺទេ ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសលើជនជាប់ចោទថា: ក្រោយពីបានស្តាប់ការសួរដេញដោលក្នុងអង្គសវនាការរួចមក ឃើញថា កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ នៅចំណុចភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង ឈ្មោះ [redacted] ភារម្យ បានមកខ្ចីប្រាក់ពីឈ្មោះ [redacted] ស្រីមុំ ចំនួន ៥០.០០០ "ប្រាំម៉ឺន" **ដុល្លារអាមេរិក** ដោយបង់ការប្រាក់ចំនួន **៧%** ក្នុង ០១ខែ ដោយធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវ ហើយដើម្បីធានាលើបំណុល ឈ្មោះ [redacted] ភារម្យ ក៏បានយកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ លេខ: ០៩០៥០១០ -០៥០០ ចំនួន ០១ច្បាប់ (ថតចម្លង) ប្រគល់ឲ្យទៅឈ្មោះ [redacted] ស្រីមុំ ថែរក្សា ។ ក្នុងអំឡុងពេលនៃការខ្ចីប្រាក់នេះ ឈ្មោះ [redacted] ភារម្យ ពុំបានបង់ការប្រាក់ឲ្យទៅឈ្មោះ [redacted] ស្រីមុំ ទៀងទាត់នោះទេ ហើយនៅពេលឈ្មោះ [redacted] ស្រីមុំ ទៅទារប្រាក់ គឺឈ្មោះ [redacted] ភារម្យ តែងតែគេចវេសរហូត ។

ក្នុងនាមជាតំណាងអយ្យការ សុំរក្សាបទចោទប្រកាន់របស់ខ្លួនតាមដីកាសន្និដ្ឋានស្ថាពរ លេខ: **៧១ អ.យ/២១** ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១ និងស្នើសុំឲ្យតុលាការផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ភារម្យ ទៅតាមច្បាប់ ។

-សេចក្តីសន្និដ្ឋានរបស់ឈ្មោះ [redacted] **គីមឈៀវ**, ឈ្មោះ [redacted] **ឈុនលីម**, ឈ្មោះ [redacted] **ចំន្ទលីដា** ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ សំណូមពរសុំឲ្យតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំទាមទារសំណង ចំនួន **៧០.០០០** "ប្រាំពីរម៉ឺន" ដុល្លារអាមេរិក និងសំណងជម្ងឺចិត្ត ចំនួន ២.០០០ "ពីរពាន់" ដុល្លារ**អាមេរិក** ពីឈ្មោះ [redacted] ភារម្យ មកឲ្យកូនក្តីឈ្មោះ [redacted] ស្រីមុំ ។

<u>សម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ</u>

-ជនជាប់ចោទឈ្មោះ [redacted] ភារម្យ សំណូមពរសុំឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់ខ្លួន ដើម្បីខ្លួនបានឆាប់មានសេរីភាពចូលរួមរស់នៅក្នុងសង្គមវិញ ។

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយជនចាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

<u>ក្រោយពីបានពិនិត្យសំណុំរឿងនិងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ</u>

<u>សាលាដំបូងខេត្តកោះកុង</u>

<u>យល់ឃើញថា:</u>

-កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០០១៩ នៅចំណុចភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង មានអំពើល្មើស ឆបោក ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ ហេង ភារម្យ បានខ្ចីប្រាក់ពីឈ្មោះ [redacted] ស្រីមុំ ចំនួន ៥០.០០០ " ប្រាំម៉ឺន" ដុល្លារអាមេរិក ដោយបង់ការប្រាក់ចំនួន ៧% ក្នុង ០១ខែ និងធ្វើកិច្ចសន្យាខ្ចីប្រាក់ត្រឹមត្រូវ ហើយដើម្បីធានាលើបំណុល ឈ្មោះ [redacted] ភារម្យ ក៏បានយកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ លេខ: ០៩០៥០១០

-០៥០០ ចំនួន ០១ច្បាប់ (ថតចម្លង) ប្រគល់ឲ្យទៅឈ្មោះ [redacted] ស្រីមុំ ថែរក្សា ។ បន្ទាប់ពីខ្ចីរួច ឈ្មោះ [redacted] ភារម្យ ពុំបានបង់ការប្រាក់ឲ្យទៅឈ្មោះ [redacted] ស្រីមុំ ទៀងទាត់នោះទេ នៅពេលឈ្មោះ ឃាក់ ស្រីមុំ ទៅទារប្រាក់ គឺឈ្មោះ ហេង ភារម្យ តែងតែឆ្លើយគេចវេសរហូត។

ចំពោះអំពើល្មើសនេះ ត្រូវច្បាប់បញ្ញត្តិចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ និង ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-នាពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ បានឆ្លើយថា កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ ឈ្មោះ [redacted] ភារម្យ បានមកខ្ចីចងការប្រាក់ពីខ្លួន ចំនួន ៥០.០០០ "ប្រាំម៉ឺន" ដុល្លារអាមេរិក និងបានធ្វើកិច្ចសន្យាខ្ចីប្រាក់ ចំនួន ០២លើក ក្នុងថ្ងៃតែមួយ គឺថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ លើកទី ១ ចំនួន ២០.០០០ "ពីរម៉ឺន" ដុល្លារអាមេរិក, លើកទី ២ ចំនួន ៣០.០០០ "បីម៉ឺន" ដុល្លារអាមេរិក ដោយបង់ប្រាក់ចំនួន ៧% ស្មើនឹង ៣៥០០ "បីពាន់ប្រាំរយ" ដុល្លារអាមេរិក និងមានសាក្សីឈ្មោះ [redacted] សារិន ជាអធិការស្រុកមណ្ឌលសីមា ខេត្តកោះកុង ចុះហត្ថលេខានឹងលី និងទទួលស្គាល់ថាឈ្មោះ [redacted] ភារម្យ បានខ្ចីប្រាក់ពីខ្លួន ចំនួន ៥០.០០០ "ប្រាំម៉ឺន" ដុល្លារអាមេរិក ពិតមែន ដោយឈ្មោះ [redacted] ភារម្យ បានយកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខៈ ០៩០៥០១០-០៥០០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩ (ថតចម្លង) ដាក់បញ្ចាំនៅនឹងខ្លួន ។ មូលហេតុដែលខ្លួនទុកចិត្តទទួលយកប្លង់ (ថតចម្លង) គឺដោយសារតែ ឈ្មោះ [redacted] ភារម្យ បានអះអាងថា ប្លង់ពិតគឺនៅធនាគារ កាណាឌីយ៉ា ចាំទៅលួសប្លង់ពិតមកឲ្យខ្លួនវិញ ហើយម្យ៉ាងទៀត ឈ្មោះ [redacted] ភារម្យ ជាមិត្តភក្តិជិតស្និតរបស់ខ្លួន ទើបខ្លួនជឿទុកចិត្តឲ្យខ្ចីប្រាក់ ។ ឈ្មោះ [redacted] ភារម្យ បានបង់ប្រាក់ការឲ្យមកខ្លួន ត្រឹមតែ ០២ ខែប៉ុណ្ណោះ ក្រោយមកក៏មិនបានបង់ឲ្យខ្លួនទេ ។ រហូតចូលដល់ក្នុងខែ កញ្ញា ឆ្នាំ ២០១៩ ឈ្មោះ [redacted] ភារម្យ បានខ្ចីប្រាក់ពីខ្លួន ចំនួន ១០.០០០ "មួយម៉ឺន" ដុល្លារអាមេរិកទៀត តែមិនបានធ្វើកិច្ចសន្យាទេ ។ ក្រោយមកនៅក្នុង មីនា ឆ្នាំ ២០២០ បានឲ្យឈ្មោះ [redacted] ភារម្យ ខ្ចីប្រាក់បន្ថែមទៀត ចំនួន ១២.០០០ "មួយម៉ឺនពីរពាន់" ដុល្លារអាមេរិក ដោយខ្លួនបានយកប្លង់ផ្ទះជាឈ្មោះរបស់ខ្លួនផ្ទាល់ទៅដាក់បញ្ចាំនៅនឹងគេ ដើម្បីយកប្រាក់មកឲ្យឈ្មោះ [redacted] ភារម្យ ខ្ចី ។ បន្ទាប់មកនៅថ្ងៃខែឆ្នាំមិនចាំ ឈ្មោះ [redacted] ភារម្យ បានមកខ្ចីប្រាក់ពីម្តាយក្មេកខ្លួន ចំនួន ៥០០ "ប្រាំរយ" ដុល្លារ ថែមទៀត សរុបប្រាក់ដើមជំពាក់ គឺចំនួន ៧២.៥០០ "ប្រាំពីរម៉ឺនពីរពាន់ប្រាំរយ" ដុល្លារអាមេរិក ។ សំណូមពរ សុំប្តឹងទាមទារប្រាក់ជំពាក់ ចំនួន ៧០.០០០ "ប្រាំពីរម៉ឺន" ដុល្លារអាមេរិក និងសំណងជម្ងឺចិត្ត ចំនួន ២.០០០ "ពីរពាន់" ដុល្លារអាមេរិក ពីឈ្មោះ [redacted] ភារម្យ ។

-ជនជាប់ចោទឈ្មោះ [redacted] ភារម្យ បានឆ្លើយសារភាពក្នុងពេលសវនាការថា កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ខ្លួនពិតជាបានធ្វើកិច្ចសន្យាខ្ចីប្រាក់ពីឈ្មោះ [redacted] ស្រីមុំ ចំនួន ៥០.០០០ "ប្រាំម៉ឺន" ដុល្លារអាមេរិក ដោយបានធ្វើកិច្ចសន្យាចំនួន ០២លើក ក្នុងថ្ងៃតែមួយ គឺថ្ងៃ ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ លើកទី ចំនួន ២០.០០០ "ពីរម៉ឺន" ដុល្លារអាមេរិក, និងលើកទី ២ ចំនួន ៣០.០០០ (បីម៉ឺន) ដុល្លារអាមេរិក និងឲ្យការប្រាក់ចំនួន ៧% ស្មើនឹង ៣៥០០ "បីពាន់ប្រាំរយ" ដុល្លារអាមេរិក មានសាក្សីឈ្មោះ [redacted] សារិន ជាអធិការស្រុកមណ្ឌលសីមា ខេត្តកោះកុង ចុះហត្ថលេខានឹងលី និងទទួលស្គាល់ថាខ្លួន បានខ្ចីប្រាក់ពីឈ្មោះ [redacted] ស្រីមុំ ចំនួន ៥០.០០០ "ប្រាំម៉ឺន" ដុល្លារអាមេរិក ប្រាកដមែន ។ ដោយខ្លួនបានយកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខៈ ០៩០៥០១០-០៥០០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩ (ថតចម្លង) ដាក់បញ្ចាំនឹងឈ្មោះ [redacted] ស្រីមុំ ហើយឈ្មោះ [redacted] ស្រីមុំ ក៏បានដឹងថា វិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខៈ ០៩០៥០១០-០៥០០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩ នេះ ជាច្បាប់ចម្លង ហើយវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខៈ ០៩០៥០១០-០៥០០ ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៩ ដែលជាច្បាប់ដើម នៅជាប់នៅធនាគារផងដែរ ។ ក្រោយមកទៀត ខ្លួនពិតជាបាន

នូវប្រាក់ពីឈ្មោះ [redacted] ស្រីមុំ បន្ថែមទៀត ចំនួន ២២.៥០០ "ពីរម៉ឺនពីរពាន់ប្រាំរយ" ដុល្លារអាមេរិក សរុបទាំងអស់ គឺចំនួន ៧២.៥០០ "ប្រាំពីរម៉ឺនពីរពាន់ប្រាំរយ" ដុល្លារអាមេរិក ពិតប្រាកដមែន ។

-ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ និងចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ភារម្យ, សាក្សី ឃើញថា មានភាពស៊ីសង្វាក់ទៅនឹងភស្តុតាង, ឯកសារនានា មាននៅក្នុងសំណុំរឿង ដែលអាចឲ្យតុលាការជឿបានថា ជនជាប់ចោទឈ្មោះ [redacted] ភារម្យ ពិតជាបានប្រព្រឹត្តអំពើ ឆបោក នៅចំណុចភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ ដូចដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់ពិតប្រាកដមែន ។

-អំពើនេះធ្វើឲ្យខូចរបៀបរៀបរយសាធារណៈ សណ្តាប់ធ្នាប់សង្គម, ប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ, ប៉ះពាល់កិត្តិយសសេចក្តីថ្លៃថ្នូរ, និងប៉ះពាល់ដល់និន្នាការអាក្រក់ក្នុងសង្គមនៃព្រះរាជាណាចក្រកម្ពុជា ។

-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នៅតែរក្សាបទចោទប្រកាន់ទុកជាបានការទាំងស្រុងដដែល និងសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់ ។

-ដើមបណ្តឹងរដ្ឋប្បវេណី សុំប្តឹងទាមទារប្រាក់ដើមពាក់ ចំនួន ៧០.០០០ "ប្រាំពីរម៉ឺន" ដុល្លារអាមេរិក និងសំណងជម្ងឺចិត្ត ចំនួន ២.០០០ "ពីរពាន់" ដុល្លារអាមេរិក ពីឈ្មោះ ហេង ភារម្យ គប្បីតុលាការសម្រេចតាមការស្នើសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ ។

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណី សំណូមពរសុំឲ្យតុលាការ សម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ និងសុំទាមទារសំណង ចំនួន ៧០.០០០ "ប្រាំពីរម៉ឺន" ដុល្លារអាមេរិក និងសំណងជម្ងឺចិត្ត ចំនួន ២.០០០ "ពីរពាន់" ដុល្លារអាមេរិក ពីឈ្មោះ [redacted] ភារម្យ មកឲ្យកូនក្តីខ្លួនឈ្មោះ [redacted] ស្រីមុំ ។

-សម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ សំណូមពរសុំបន្ធូរបន្ថយទោស ព្រោះខ្លួនដឹងកំហុសហើយ ។

-សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ និងសម្តីចុងក្រោយបង្អស់របស់ជនជាប់ចោទ គប្បីតុលាការពិចារណា ។

-ជនជាប់ចោទ ជាជនស្លូតត្រង់ ទើបតែប្រព្រឹត្តបទល្មើសជាលើកទីដំបូង មានស្មារតី គ្រប់គ្រាន់ យល់ដឹងពីអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ភារម្យ ពីបទ ឆបោក ប្រព្រឹត្តនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ , ៣៧៨ នៃក្រមព្រហ្មទណ្ឌ

## <u>ហេតុដូច្នេះសាលាដំបូងខេត្តកោះកុង</u>

## <u>វិនិច្ឆ័យសេចក្តី</u>

១/ -<u>ផ្តន្ទាទោស:</u> ឈ្មោះ [redacted] ភារម្យ ភេទស្រី អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារ កំណត់ ០១ (មួយ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ និងពិន័យប្រាក់ចំនួន ១.០០០.០០០ "មួយលាន" រៀល ពីបទ ឆបោក ប្រព្រឹត្តនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង កាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៣៧៧ , ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២/ -បង្គាប់ឲ្យឈ្មោះ [redacted] ភារម្យ សងប្រាក់ដើមពាក់ចំនួន ៧០.០០០ "ប្រាំពីរម៉ឺន" ដុល្លារអាមេរិក និងប្រាក់សំណងជម្ងឺចិត្ត ចំនួន ២.០០០ "ពីរពាន់" ដុល្លារអាមេរិក ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ ។

៣/-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០២១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ភារម្យ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីមុំ , បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខានិងត្រា [redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខានិងត្រា [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ០៩រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
កោះកុង, ថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២១
ក្រឡាបញ្ជីសវនាការ

[redacted]

បានឃើញ
ចៅក្រមជំនុំជម្រះ

[redacted]